# សេចក្តីប្រកាសព័ត៌មាន

## កិច្ចប្រជុំពិភពលោកស្តីពីមីនបានបញ្ចប់ដោយជោគជ័យនិងការតាំងចិត្តជាថ្មី

*រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១* – កិច្ចប្រជុំពិភពលោកស្តីពីបញ្ហាមីនសាកល ដែលបានជួបប្រជុំប្រតិភូជាង ១.០០០ នាក់នៅរាជធានីភ្នំពេញ បានបញ្ចប់នាថ្ងៃនេះ ដោយកត់សម្គាល់នូវវឌ្ឍនភាពគួរឲ្យរំភើបឆ្ពោះទៅកាន់ពិភពលោកគ្មានគ្រាប់មីនមួយ និងដោយមានការតាំងចិត្តជាថ្មី ដ៏រឹងមាំក្នុងការជំនះបញ្ហាប្រឈមនានាដែលនៅសេសសល់។

"កិច្ចប្រជុំលើកទី១១ នៃរដ្ឋភាគី (11MSP) នៃអនុសញ្ញាហាមប្រាមការប្រើគ្រាប់មីនប្រឆាំងមនុស្ស គឺជាជោគជ័យដ៏ធំមួយ" ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីកម្ពុជា និង ជាប្រធានកិច្ចប្រជុំ 11MSP បានមានប្រសាសន៍។ "យើងបានស្រង់យកភាពខ្លាំងនៃអតីតកាលនៃចលនានេះ ដើម្បីធ្វើការតាំងចិត្តដ៏ខ្លាំងក្លាស្មើដៃគ្នាមួយចំពោះអនាគត។ យើងនៅតែយកចិត្តទុកដាក់លើការបញ្ឈប់ការឈឺចាប់និងការរងគ្រោះថ្នាក់បណ្តាលមកពីគ្រាប់មីនប្រឆាំងមនុស្ស" ។

នៅក្នុងរបាយការណ៍ចុងក្រោយនៃកិច្ចប្រជុំ 11MSP រដ្ឋភាគីទាំង ១៥៨ នៃអនុសញ្ញា បានឯកភាពគ្នាលើការ "ការតាំងចិត្តឡើងវិញ ទោះបីជានៅក្នុងពេលមានការលំបាកខាងហិរញ្ញវត្ថុក្តី ចំពោះការសម្រេចឲ្យបាននូវពិភពលោកមួយគ្មានគ្រាប់មីនប្រឆាំងមនុស្ស ដែលនៅក្នុងនោះ សិទ្ធិរបស់មនុស្សគ្រប់រូបត្រូវបានគោរព ហើយស្ត្រី កុមារ និង បុរសទាំងអស់អាចរស់នៅក្នុងសេចក្តីថ្លៃថ្នូរនិងវិបុលភាព។

ខណៈដែលបញ្ហាប្រឈមនៃសេដ្ឋកិច្ចពិភពលោកគឺជាបន្ទុកដ៏ធ្ងន់នៅក្នុងអារម្មណ៍របស់ប្រតិភូ ឯកឧត្តម ប្រាក់ សុខុន បានចេញសេចក្តីអំពាវនាវដ៏ខ្លាំងមួយចំពោះសហគមន៍អន្តរជាតិ សូមឲ្យគោរពកិច្ចសន្យារបស់ខ្លួនក្នុងការជួយគាំទ្រគោលដៅនៃអនុសញ្ញា។ "យើងបានឯកភាពគ្នា ដោយគ្មានឱសានវាទឬហួសកាលបរិច្ឆេទ លើកិច្ចសហប្រតិបត្តិការ និង ការជួយគ្នាទៅវិញទៅមក ក្នុងការសម្រេចបានចក្ខុវិស័យនៃលិខិតូបករណ៍មនុស្សធម៌ដ៏សំខាន់នេះ" ឯកឧត្តមបានមានប្រសាសន៍។ "ខណៈដែលរដ្ឋាភិបាលទទួលខុសត្រូវមិនត្រូវបែរខ្នងចំពោះស្ថានភាពហិរញ្ញវត្ថុជាក់ស្តែង ដូចគ្នានេះដែរ យើងមិនត្រូវខកខានចំពោះកាតព្វកិច្ចរបស់យើងឡើយ។"

រដ្ឋភាគីមួយចំនួននៃអនុសញ្ញាបានឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់ឯកឧត្តមប្រធានកិច្ចប្រជុំ 11MSP។

- ប្រទេសហូឡង់បានប្រកាសថា "ទោះបីជាមានការកាត់បន្ថយចំណាយនៅក្នុងវិស័យដ៏ទៃក្តី ក៏រដ្ឋាភិបាលនៅតែជឿជាក់លើកិច្ចការនេះ" និងបានរាយការណ៍ថាប្រទេសហូឡង់មានបំណងរក្សាវិភាគទានប្រចាំឆ្នាំចំនួន ១៥ លានអឺរ៉ូរបស់ខ្លួនចំពោះការដោះមីន និង ជំនួយជនរងគ្រោះ។

**AP Mine Ban Convention Implementation Support Unit**

GICHD | 7bis, avenue de la Paix | P.O. Box 1300 | 1211 Geneva 1 | Switzerland | t. + 41 (0) 79 960 2274
f. + 41 (0)22 906 16 90 | isu@apminebanconvention.org | **www.apminebanconvention.org** | **www.11msp.org**

- ប្រទេសអូទ្រីសបានប្រកាសថា "ទោះបីជាមានវិបត្តិហិរញ្ញវត្ថុជារួមក្តី ក៏យើងបានបង្កើនបន្តិចដែរនៅក្នុងកម្រិតផ្តល់ហិរញ្ញប្បទានរបស់យើងដល់សកម្មភាពមីនជាក់លាក់នៅក្នុងឆ្នាំ ២០១២ ឡើងដល់ ១,៩ លានអឺរ៉ូ។ ប្រទេសអូទ្រីសក៏បានរាយការណ៍ផងដែរនូវវិភាគទានដំបូងបំផុតរបស់ខ្លួនដល់ការដោះមីននិងជំនួយជនរងគ្រោះនៅកម្ពុជា ដោយបានប្រកាសវិភាគទានដែលមានទឹកប្រាក់សរុបចំនួន ៤០០.០០០ អឺរ៉ូ។
- បន្ថែមលើនេះ ប្រទេសនូវែលសេឡង់ បានប្រកាសថាវានឹងរួមវិភាគទានជាង ១ លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០១២ សម្រាប់គម្រោងបោសសម្អាតមីននៅភូមិភាគឥសាននៃប្រទេសកម្ពុជា។

កិច្ចសហប្រតិបត្តិការត្បូង-ត្បូង ក៏ស្ថិតនៅក្នុងលំដាប់អាទិភាពកំពូលសម្រាប់ប្រតិភូផងដែរ។

- ប្រទេសប្រេស៊ីលបានគូសបញ្ជាក់ថាខ្លួនរួមវិភាគទានប្រហែល ៤៦ ភាគរយនៃធនធានទាំងអស់សម្រាប់កិច្ចប្រឹងប្រែងបោសសម្អាតមីន ដែលត្រូវបានអនុវត្តដោយអង្គការនានារបស់សហរដ្ឋអាមេរិក។
- បន្ថែមលើនេះ ប្រទេសអេក្វាឌ័រ និង ប៉េរូ បានប្រកាសថាភាពជាដៃគូរបស់ខ្លួនក្នុងការដោះមីននៅតំបន់ព្រំដែនរួមនឹងបន្ត។

បន្ថែមលើការអះអាងឡើងវិញនូវការតាំងចិត្តចំពោះការជំនះបញ្ហាអនាគត កិច្ចប្រជុំ 11MSP បានកត់សម្គាល់វឌ្ឍនភាពដ៏ធំក្នុងការអនុវត្តតាមគោលដៅស្នូលនៃអនុសញ្ញា។

- កិច្ចប្រជុំ 11MSP បានអបអរសាទរដែល ប្រទេសទូវ៉ាលូ និង ស៊ូដង់ខាងត្បូង បានអង្គុយលើអសនៈរបស់ខ្លួនជារដ្ឋភាគីថ្មីនៃអនុសញ្ញា។
- បន្ថែមលើនេះ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសហ្វាំងឡង់ បានប្រកាសថាប្រទេសហ្វាំងឡង់នឹងក្លាយជារដ្ឋសមាជិកទី ១៥៩ ដែលចូលក្នុងអនុសញ្ញា។
- រដ្ឋចំនួន (១៥) ដែលមិនទាន់បានចូលរួមក្នុងអនុសញ្ញា បានចូលរួមក្នុងកិច្ចប្រជុំ 11MSP ក្នុងឋានៈជាអ្នកសង្កេតការណ៍ ដោយផ្តល់សញ្ញានៃការបើកទូលាយរបស់ខ្លួន ក្នុងការចូលរួមក្នុងការពិភាក្សាស្តីពីផលប៉ះពាល់បំផ្លិចបំផ្លាញនៃគ្រាប់មីនប្រឆាំងមនុស្ស។
- នៅក្នុងចំណោមប្រទេសទាំងនេះ សហរដ្ឋអាមេរិក បានរាយការរណ៍ថាខ្លួនកំពុងបន្តពិនិត្យមើលឡើងវិញនូវគោលនយោបាយគ្រាប់មីនរបស់ខ្លួន ហើយប្រទេសមីយ៉ាន់ម៉ាបានលើកឡើងថា "ការសិក្សាដ៏មធ្យ័តលើអនុសញ្ញានេះនឹងត្រូវបានបន្ត។"
- ប្រទេសទួរគី បានរាយការណ៍អំពីការបំផ្លាញគ្រាប់មីនប្រឆាំងមនុស្សក្នុងឃ្លាំងទាំងអស់ ដោយមានគ្រាប់មីនប្រហែល ៣ លាន គ្រាប់ត្រូវបានបំផ្លាញ។
- ប្រទេសប៊ុរុនឌី និង នីហ្សេរីយ៉ា បានប្រកាសការបញ្ចប់កាតព្វកិច្ចបោសសម្អាតមីនរបស់ខ្លួន។
- ម្យ៉ាងទៀត ប្រទេសហ្គីណេប៊ីសាវ ហ្សកដានី និង អ៊ុយហ្គង់ដា បានប្រកាសថាពួកគេនឹងបញ្ចប់កម្មវិធីបោសសម្អាតមីនរបស់ខ្លួនក្នុងបណ្តាខែខាងមុខនេះ។

- រដ្ឋភាគីជាង ២០ ដែលទទួលបន្ទុកលើចំនួនជនរងគ្រោះដោយគ្រាប់មីនជាច្រើននាក់ បានរាយការណ៍អំពីកិច្ចប្រឹងប្រែងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ជនរងគ្រោះ និង ធានាសិទ្ធិរបស់ពួកគេ។ ប្រទេសកម្ពុជា ក្នុងឋានៈជាប្រទេសមួយនៃប្រទេសរងផលប៉ះពាល់ខ្លាំងជាងគេ បានគូសបញ្ជាក់ថាខ្លួនកំពុងវាយតម្លៃផែនការសកម្មភាពជាតិរបស់ខ្លួនស្តីពីពិការភាព សំដៅរៀបចំផែនការកែសម្រួលថ្មីមួយក្នុងឆ្នាំ ២០១២។

## សេចក្តីសម្រេចចិត្តរបស់កិច្ចប្រជុំ 11MSP

នៅថ្ងៃចុងក្រោយនៃកិច្ចប្រជុំ 11MSP កិច្ចប្រជុំបានបញ្ចប់របាយការណ៍វឌ្ឍនភាពភ្នំពេញ ដែលគឺជាសេចក្តីអធិប្បាយដ៏ពេញលេញនូវវឌ្ឍនភាពនៅក្នុងការអនុវត្តតាមគោលដៅនៃអនុសញ្ញាក្នុងឆ្នាំ២០១១។ បន្ថែមលើនេះ កិច្ចប្រជុំ 11MSP បានសម្តែងជាចុងក្រោយនូវ "ការបារម្ភដ៏ជ្រាលជ្រៅអំពីការប្រើប្រាស់ថ្មីនូវគ្រាប់មីនប្រឆាំងមនុស្ស" និងបានស្នើសូមឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិសរសេរទៅកាន់រដ្ឋមិនមែនភាគីនៃអនុសញ្ញា "ដើម្បីជម្រុញយ៉ាងខ្លាំងក្លាសូមឲ្យរដ្ឋទាំងនោះផ្តល់សច្ចាប័នលើការចូលក្នុងអនុសញ្ញា។

កិច្ចប្រជុំបានឯកភាពលើសំណើពន្យារការិយបរិច្ឆេទបោសសម្អាតមីន ដូចខាងក្រោមៈ

- ប្រទេសអាល់សេរីៈ កិច្ចប្រជុំបានកត់សម្គាល់ថាសំណើរបស់ប្រទេសអាល់សេរីសុំពន្យារពេលរហូតដល់ថ្ងៃទី ១ មេសា ឆ្នាំ ២០១៧ហាក់បីដូចជា "អាចអនុវត្តបាន" ចំពោះបញ្ហាប្រឈមផ្នែកបច្ចេកទេសដែលប្រទេសនោះជួបប្រទះនៅក្នុងចម្ការមីនចំនួនបី។

- ប្រទេសឈីលី ត្រូវបានផ្តល់ការពន្យារពេលដល់ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០២០ ដោយរដ្ឋភាគីមានទំនុកចិត្តថាចំពោះមុខកិច្ចដំណើរការល្អរបស់ឈីលីក្នុងការរំដោះដី ប្រទេសនេះអាច "ដំណើរការអនុវត្តបានលឿនជាងរយៈពេលដែលបានស្នើ។"
- ប្រទេសកុងហ្គោ (ប្រាសាវីល)ៈ កិច្ចប្រជុំបានឯកភាពដោយ "ក្តីសោកស្តាយ" លើការផ្តល់សំណើសម្រាប់ការពន្យារពេលមួយរហូតដល់ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៣។ កិច្ចប្រជុំ បានសម្តែង "ការបារម្ភ" ចំពោះការដាក់សំណើយឺត ដែលត្រូវបានបង្ហាញដោយកុងហ្គោ និង ថាប្រការនេះមានន័យថាពីថ្ងៃទី ១ វិច្ឆិកា ដល់ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១ កុងហ្គោមិនបានគោរពតាម។
- សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (DRC) និង អេរីត្រេៈ កិច្ចប្រជុំបានកត់សម្គាល់ថា "ថ្វីបើមានលក្ខណៈគួរឲ្យស្តាយដែលក្រោយពេលជិតដប់ឆ្នាំចាប់តាំងពីចូលជាធរមាន រដ្ឋភាគីមួយមិនអាចទទួលខុសត្រូវលើអ្វីដែលត្រូវធ្វើបន្ត ក៏វាគឺជាចំណុចវិជ្ជមានដែរដែលរដ្ឋទាំងពីរមានបំណងចាត់វិធានការដើម្បីយល់ពីកម្រិតជាក់ស្តែងនៃបញ្ហាប្រឈម។" ការិយបរិច្ឆេទថ្មីនៃសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោសម្រាប់ការបោសសម្អាតមីនត្រូវបានកំណត់នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៥, សម្រាប់ប្រទេសអារីត្រេនៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៥។

ចំណុចពិសេសមួយនៃកិច្ចប្រជុំ 11MSP គឺសម័យប្រជុំពិសេសមួយដែលរំលឹកកិច្ចប្រឹងប្រែងរយៈពេលពីរទសវត្សរ៍ក្នុងការលុបបំបាត់មីន និង ដែលបានបង្ហាញតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល និង ជនរួចរស់ពីគ្រាប់មីន ដែលនៅពេលនេះត្រូវបានចាត់ទុកជា "ភាគីស្មើភាព" ដោយអនុសញ្ញា។ អ្នកដោះមីន ជនរួចជីវិតសកម្មជន និង តំណាងនៃរដ្ឋចំនួន ៤០ នាក់ដែលបានជួយបង្កើតចលនា បានដើរតួសំខាន់។ ឯកឧត្តម ប្រាក់ សុខុន បានកត់សម្គាល់ថា "មេរៀនទីមួយនៃចលនានេះ គឺការពិនិត្យមើលបញ្ហាតាមទស្សនៈខុសគ្នាមួយ។ ដោយដាក់ទិដ្ឋភាពមនុស្សចំពោះបញ្ហានេះ យើងបានបញ្ជាក់ច្បាស់ចំពោះពិភពលោកថារឿងនេះមិនមែនជាបញ្ហាយោធាមួយទេ។ បញ្ហានេះគឺជាបញ្ហាមនុស្សធម៌មួយ។"

## អនុសញ្ញាហាមប្រាមការប្រើគ្រាប់មីនប្រឆាំងមនុស្ស

The អនុសញ្ញាហាមប្រាមការប្រើគ្រាប់មីនប្រឆាំងមនុស្ស ត្រូវបានអនុម័តក្នុងក្រុងអូស្លូក្នុងឆ្នាំ ១៩៩៧ បានបើកសម្រាប់ការចុះហត្ថលេខាក្នុងក្រុងអូតាវ៉ាក្នុងឆ្នាំដដែល និង បានចូលជាធរមានក្នុងឆ្នាំ ១៩៩៩។

មកដល់បច្ចុប្បន្ននេះ មានរដ្ឋចំនួន ១៥៨ បានចូលរួមក្នុងអនុសញ្ញានេះ ដោយមានប្រទេសចំនួន ១៥៥ នៃបណ្តាប្រទេសទាំងនេះបានរាយការណ៍ថាពួកគេលែងមានស្តុកគ្រាប់មីនប្រឆាំងនឹងមនុស្សទៀតហើយ។ គ្រាប់មីនក្នុងឃ្លាំងជាង ៤៤,៥ លានគ្រាប់ត្រូវបានបំផ្លាញដោយរដ្ឋភាគី។

រដ្ឋចំនួន ៣៤ នៃរដ្ឋចំនួន ៥០ ដែលកាលពីមុនបានផលិតមីនប្រឆាំងមនុស្ស នៅពេលនេះ ត្រូវជាប់កាតព្វកិច្ចដោយការហាមឃាត់នៃអនុសញ្ញាលើការផលិត។ ភាគីដទៃទៀតភាគច្រើនបានដាក់ឪសានុវាទលើការផលិត និង/ឬ ការផ្ទេរគ្រាប់មីន។

ការបោសសម្អាតគ្រាប់មីនបានធ្វើឲ្យផ្ទៃដីរាប់លានម៉ែត្រការ៉េដែលកាលពីមុនគឺជាដីមានគ្រោះថ្នាក់ ត្រូវបានសម្អាតសម្រាប់សកម្មភាពធម្មតារបស់មនុស្ស។

###

សម្រាប់បទសម្ភាសន៍ ឬ ព័ត៌មានបន្ថែមអំពីអនុសញ្ញា សូមសរសេរអ៊ីម៉េលទៅកាន់៖
ISU@APMineBanConvention.org ឬ ទាក់ទងឡាយឡា រ៉ូឌ្រីហ្គេស(Laila Rodriguez) តាមទូរស័ព្ទលេខ +855 97 6890 977 ឬ +41 79 960 2274។ សូមតភ្ជាប់ទៅនឹងអនុសញ្ញាតាមរយៈគេហទំព័ររបស់យើង website, Facebook, Flickr ឬ Twitter ។